Khmer

# ក្រដាសហេតុការណ៍នៃសុវត្ថិភាពភ្លើងឆេះមុនដំបូង




## ត្រូវរៀបចំប្រឈមនឹងភ្លើងឆេះ

ការត្រៀមខ្លួនហើយនិងការបង្ការគឺជាគន្លឹះដ៏សំខាន់ចំពោះបរិស្ថានរស់នៅដែលមានសុវត្ថិភាព។ ផ្ទះសម្បែងនិងមជ្ឈមណ្ឌលត្រូវមានផែនការគេចចេញនៃភ្លើងឆេះ។ នៅកន្លែងធ្វើការ ច្បាប់ខាងសុខភាពការងារនិងសុវត្ថិភាពធ្វើឲ្យមានការចាំបាច់សំរាប់ពាណិជ្ជកម្មនិងអង្គការទាំងឡាយឲ្យមានផែនការគេចចេញនៃភ្លើងឆេះនៅទីកន្លែង ហើយនិងត្រូវធ្វើតេស្តផែនការនេះតាមមូលដ្ឋានឲ្យបានទៀងទាត់ ក៏ប៉ុន្តែនៅតាមផ្ទះវិញ យើងទុកចិត្តលើគ្រួសារទាំងឡាយធ្វើកិច្ចការនេះសំរាប់ខ្លួនឯង។

### ធ្វើឲ្យប្រាកដថាសមាជិកនៅក្នុងផ្ទះសម្បែងចេះ៖

- រៀបលូនក្រាបទាបនៅក្នុងផ្សែង
- រៀបផ្សេងៗដើម្បីចាកចេញពីបន្ទប់នីមួយៗនិងពីផ្ទះផង
- រៀបបើកសោទ្វារនិងបង្អួច
- រៀបទូរស័ព្ទហៅរថយន្តពន្លត់ភ្លើង - 000
- ដឹងកន្លែងជួបជុំគ្នានៅក្រៅផ្ទះ (ដូចជា ប្រអប់សំបុត្រ)
- ការហាត់គឺជាគន្លឹះដ៏សំខាន់ - គួរហាត់ជាមូលដ្ឋានប្រចាំខែ

### ត្រូវរៀបចំប្រឈមនឹងភ្លើងឆេះ

- មានតែគ្រឿងឲ្យសញ្ញាពេលមានផ្សែងដែលដំណើរការប៉ុណ្ណោះជួយសង្គ្រោះជីវិត។ រក្សាវាកុំឲ្យមានធូលីហើយនិងដូរថ្មនៅដំណាច់ការសំចៃពន្លឺថ្ងៃ
- ធ្វើតេស្តគ្រឿងឲ្យសញ្ញាពេលមានផ្សែងរបស់លោកអ្នករៀងរាល់អាទិត្យ ហើយនិងសំអាតវារៀងរាល់ខែ
- ត្រូវយល់ដឹងថាក្មេងក្រោមអាយុប្រាំឆ្នាំ ជានិច្ចកាលមិនព្រួសរសម្លេងនៃគ្រឿងឲ្យសញ្ញាពេលមានផ្សែងនេះទេ
- សូមរក្សាទុកនូវភួយពេលភ្លើងឆេះ និង/ឬ គ្រឿងពន្លត់ភ្លើងនៅក្នុងចង្ក្រានបាយ ហើយនិងចេះរៀបប្រើប្រាស់វាផង
- កន្លែងដាក់ភួយពេលមានភ្លើងឆេះនិងគ្រឿងពន្លត់ភ្លើង ត្រូវដាក់នៅក្នុងចង្ក្រានបាយត្រង់ចន្លោះកន្លែងណាមួយនិងទ្វារចេញដែលភ្លើងប្រហែលជាអាចកើតមានឡើង
- សូមដាក់កុងតាក់សុវត្ថិភាពអគ្គិសនី - ត្រូវដាក់ដោយជាងភ្លើងដែលមានចុះឈ្មោះត្រឹមត្រូវ
- សូមរៀបចំធ្វើផែនការគេចចេញពេលមានភ្លើងឆេះជាមួយសមាជិកគ្រួសាររបស់លោកអ្នក ហើយនិងហាត់ដោយទៀតទាត់ផង









### ព័ត៌មានដ៏ល្អគឺ...

ជាមាតាបិតា ឬអ្នកផ្តល់ការថែទាំ លោកអ្នកអាចធ្វើបរិស្ថានរបស់ក្មេងតូចៗឲ្យមានសុវត្ថិភាពថែមទៀតដោយមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់រលាកភ្លើង រលាកទឹកក្តៅនិងភ្លើងឆេះ ហើយនិងចាត់វិធានការបង្ការគ្រោះថ្នាក់នេះ។ ក្មេងនឹងចម្លងតាមលោកអ្នកជាតួគំរូរបស់គេ ដូច្នេះធ្វើឲ្យគេឃើញលោកអ្នកកំពុងចាត់វិធានការសុវត្ថិភាព–ដូចជា ការដាក់គ្រឿងរបាំងនៅមុខកន្លែងដុតភ្លើងចំហរជាដើម។

**ក៏ប៉ុន្តែ សូមចងចាំថា.....**ក្មេងក្រោមអាយុប្រាំឆ្នាំនឹងមិនទៀងជារត់គេចចេញពីភ្លើងឆេះទេ ឬយល់ពីអ្វីខ្លះដែលត្រូវធ្វើនៅពេលមានអាសន្ន។ មាតាបិតានិងអ្នកផ្តល់ការថែទាំត្រូវការការប្រុងប្រយ័ត្នទៅលើអ្វីៗនេះនៅពេលធ្វើផែនការគេចចេញពេលមានភ្លើងឆេះ។



**ចំពោះព័ត៌មានច្រើនទៅទៀត សូមទាក់ទង៖**

CFA®

www.cfa.vic.gov.au

MFB Protecting Our Community

www.mfb.vic.gov.au


អាជ្ញាធរផ្នែកខាងពន្លត់ភ្លើង(CFA) និងក្រសួងពន្លត់ភ្លើងក្រុងនិងកិច្ចបំពេញនៅពេលអាសន្ន(MFB)ធ្វើឲ្យព័ត៌មាននិងសម្ភារៈនេះអាចប្រើប្រាស់បានក្នុងការយល់ដឹងថា លោកអ្នកមានការប្រុងប្រយ័ត្នដ៏សមហេតុផលនៅពេលប្រើប្រាស់វា។ ប្រសិនបើលោកអ្នកមានការមិនច្បាស់លាស់ណាមួយអំពីការអនុវត្តព័ត៌មាននៅក្នុងកាលៈទេសៈណាមួយរបស់លោកអ្នកនោះ លោកអ្នកគួរតែរកយោបល់ពីអ្នកមានវិជ្ជាជីវៈថែមទៀត។ (CFA)និង(MFB) មិនទទួលការខុសត្រូវទេចំពោះរបៀបដែលលោកអ្នកអនុវត្ត បកស្រាយ ឬពឹងពាក់លើព័ត៌មានដែលបានផ្តល់ជូននេះ។ (CFA)និង(MFB)មិនទទួលការខុសត្រូវលើការបាត់បង់ ឬការខូចខាតដែលជាមូលហេតុបណ្តាលមកពីការប្រើប្រាស់របស់លោកអ្នកនូវព័ត៌មាននេះ ទោះជាដោយ ភាពមិនទៀងទាត់ កំហុស ការភ្លេច ឬមូលហេតុដទៃទៀតដែលគ្មានគ្រោងទុកមកនោះ។